# ការបង្ហាញអំពីការដាំពោត

**ការសាកល្បង** ការសាកល្បង១០ដើមក្នុងមួយជួរដោយប្រើប្រាស់ NEB និង១០ដើមក្នុងជួរទីពីរដោយមិនប្រើប្រាស់អ្វីទាំងអស់

**ការណែនាំពីការប្រើប្រាស់** វិធីប្រើប្រាស់: ស្រោចទឹក

ល្បាយសូលុយស្យុង: NEB 2.5 មីលីលីត្រ/ទឹក១លីត្រ(2.5 មីលីលីត្រ/លីត្រ)

កម្រិតក្នុងការប្រើប្រាស់: ក្នុងមួយដើមស្រោច100មីលីលីត្រនៃNEB ដែលលាយជាមួយទឹករួច

ការប្រើប្រាស់: ប្រើប្រាស់តែម្តងគត់នៅពេល៣សប្តាហ៍បន្ទាប់ពីការដាំ

ការវាយតម្លៃ: ៣សប្តាហ៍បន្ទាប់ពីការប្រើប្រាស់NEB (៦សប្តាហ៍បន្ទាប់ពីការដាំ)

**ការប្រើប្រាស់ជីនិងគីមី** អនុវត្តតាមកម្មវិធីប្រើប្រាស់ជីនិងការការពារសត្វល្អិតតាមធម្មតា

**ការណែនាំក្នុងការវាយតម្លៃ** វាយតម្លៃដំណាំទាំង១០ដើមក្នុងជួរនីមួយៗ។ ប្រសិនបើអាចវាយតម្លៃទាំងឫសនិងស្លឹក (ដីកឫសយ៉ាងប្រុងប្រយ័ត្នរួចលាងទឹកអោយអស់ដី)

**កំណត់ចំណាំក្នុងពេលវាយតម្លៃ** ទំហំនៃដើម ចំនួនស្លឹកនិងផលនៃដំណាំ។ ប្រសិនបើជីកឫសសូមវាយតម្លៃទៅលើពណ៌និងទំហំនៃឫស។

**ការអនុវត្តសម្រាប់ពាណិជ្ជកម្ម** កម្រិតនៃការប្រើប្រាស់នេះសម្រាប់ការសាកល្បងឆាប់រហ័សរយៈពេល៣សប្តាហ៍តែប៉ុណ្ណោះ។ ដើម្បីធ្វើការសាកល្បងសម្រាប់យកទិន្នផលសូមប្រើប្រាស់ NEB តាមកម្រិតដែលបានណែនាំដោយ Agmor។

| | ទម្ងន់នៃឫស ១០ដើម | ទម្ងន់នៃស្លឹក ១០ដើម | សរុបឫស + ស្លឹក ១០ដើម |
|---|---|---|---|
| មិនប្រើប្រាស់ NEB | 334.2 ក្រាម | 2,114.3 ក្រាម | 2,448.5 ក្រាម |
| ប្រើប្រាស់ NEB | 674.3 ក្រាម | 3,672.3 ក្រាម | 4,346.6 ក្រាម |

## ឫសនិងដើមធំជាង ការលូតលាស់មានភាពប្រសើរជាង







ការបង្ហាញពីការដាំពោត

# ការបង្ហាញអំពីការបណ្ដុះគ្រាប់ពោត

**កម្រិតក្នុងការប្រើប្រាស់ NEB** NEB ៤មីលីលីត្រ/គ្រាប់ពោត១គីឡូក្រាម (ដាក់NEB ដោយផ្ទាល់ទៅលើគ្រាប់)

**ការណែនាំក្នុងការប្រើប្រាស់** ដាក់គ្រាប់ពោត១គីឡូក្រាមទៅក្នុងថង់មួយ។ ដាក់ NEB ៤មីលីលីត្រចូលរួចក្រឡុកគ្រាប់ពោតក្នុងថង់ចុះឡើងថ្នមៗ ដើម្បីអោយជ្រាបបានសព្វ (មានពណ៌ស្មើគ្នា)។ គ្រាប់ទាំងនោះអាចយកទៅដាំភ្លាមៗឬរក្សាទុកសម្រាប់ប្រើប្រាស់នៅពេលក្រោយ។ បរិមាណនៃNEB ដែលបានប្រើប្រាស់ទៅលើគ្រាប់មិនហើរចេញពីគ្រាប់នោះទេ។

**ការណែនាំក្នុងការវាយតម្លៃ** ៣ទៅ៤សប្តាហ៍បន្ទាប់ពីការដាំ។ វាយតម្លៃទាំង១០ដើមក្នុងជួរនីមួយៗ។ ប្រសិនបើអាចសូមវាយតម្លៃទាំងឫសនិងស្លឹក (ជីកឫសយ៉ាងប្រុងប្រយ័ត្នរួចលាងទឹកអោយអស់ដី)

**កំណត់ចំណាំ** កម្រិតនៃការប្រើប្រាស់នេះសម្រាប់តែការសាកល្បងឆាប់រហ័សរយៈពេល៣ទៅ៤សប្តាហ៍ប៉ុណ្ណោះ។ ដើម្បីធ្វើការសាកល្បងយកទិន្នផលពិតប្រាកដសូមប្រើប្រាស់ NEB តាមកម្រិតដូចដែលបានែណនាំដោយ Agmor។

